# ចិនចុះផែ ?

មានពាក្យបុរាណខ្មែរថា « ឡូឡាដូចចិនចុះផែ » មានន័យថានៅទីកន្លែងណា ដែលមានក្រុមជនចិនមករស់នៅ ឬ សំចត គឺនៅទីនោះ ច្បាស់ជាឮសូរ សំឡេងខ្ទរខ្ទាយឡើងហ៊ឹងត្រចៀក។ តែអស់ជនខ្មែរ គាត់ស៊ាំត្រចៀកទៅហើយ ព្រោះជនជាតិចិនបានមករស់កុះករនៅស្រុកខ្មែរនៅគ្រប់ទីកន្លែង តាំងពីយូរណាស់មកហើយ ហើយថែមទាំង យកស្ត្រីខ្មែរធ្វើជាភរិយាថែមទៀត។ ផ្ទុយទៅវិញ កម្រមានស្ត្រីចិន យកបុរសខ្មែរធ្វើជាស្វាមីណាស់ ព្រោះបុរសខ្មែរ ភាគច្រើនជាកសិករ ហើយ សហគមចិនជាពាណិជ្ជករ ដូច្នេះវាមានអាជីព និង ភាសាផង ជារបង ព្រោះជនខ្មែរ មិនចូលចិត្តរៀនភាសាបរទេសសោះឡើយ។ ពួកជនចិន បង្កើតទីផ្សារ ក្រោយមកក្លាយជាទីក្រុង ឬ ទីប្រជុំជនតូចធំ រីឯពួកជនខ្មែរ ជាកសិករ រស់នៅក្បែរដីស្រែ ឆ្ងាយពីទីក្រុង។ ដូច្នេះ ខ្មែរ និង ចិន រស់នៅឆ្ងាយពីគ្នា តែមានទំនាក់ទំនងនឹងគ្នា ជាការចាំបាច់ និង ជាប្រយោជន៍, ចិន ជាឈ្មួញ ជាអ្នកចងការប្រាក់ និង ខ្មែរ ជាអតិថិជន។ ភាគច្រើន កសិករខ្មែរជំពាក់បំណុលចិនរាន់ក ព្រោះជាផ្លូវទោល ដែលខ្មែរអាចខ្ចីលុយ និង សុំទិញជឿបាន យកការប្រាក់ហួសប្រមាណ។ សព្វថ្ងៃស្ថានភាព វាកាន់តែអាក្រក់ទៅទៀត គឺថា រដ្ឋខ្មែរតែម្តងជំពាក់លុយចិនរាន់ក ហើយថៅកែចិន សុទ្ធជាឧកញ៉ា ដូច្នេះពាក្យបុរាណ « ឡូឡាដូចចិនចុះផែ » វាជាបច្ចុប្បន្នភាពសំរាប់របបដឹកនាំបច្ចុប្បន្ន៕

ឧប សៅ សន្ធា    គំនិត    ៣១ តុលា ២០១៩